**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខៈ ១៨៤ ជ.គ.ល

ថ្ងៃពុធ ១៣កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្តល់សេវាសវនកម្ម និងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ការិយបរិច្ឆេទ ២០២៦-២០២៧ ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃសុក្រ ទី៥ ខែធ្នូ ឆ្នាំ២០២៥ តទៅ រៀងរាល់ម៉ោងធ្វើការ (៨:០០នាទីដល់១៦:៣០នាទី) ដល់ថ្ងៃពុធ ទី១៤ ខែមករា ឆ្នាំ២០២៦ ត្រឹមវេលាម៉ោង១៦:០០នាទី ក្នុងមួយច្បាប់តម្លៃ ៣០០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃព្រហស្បតិ៍ ទី១៥ ខែមករា ឆ្នាំ២០២៦ វេលាម៉ោង ១៤:០០នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធាន**

**ជូ ផល្លា**

ចម្លងជូនៈ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ

KINGDOM OF CAMBODIA

NATION RELIGION KING

PHNOM PENH
WATER SUPPLY AUTHORITY

N°..185..PPWSA..

Date: ...03...Dec...2025

## Invitation for Bids

Phnom Penh Water Supply Authority (PPWSA) now invites sealed bids from eligible Bidders registered in the Kingdom of Cambodia to provide the Auditor Services 2026-2027.

A complete set of bidding document is available upon payment of non-refundable fee of 300,000Riels at Procurement Unit of PPWSA with the address #45, Street 106, Sangkat Srash Chork, Khan Daun Penh, Phnom Penh, working hour from Friday 05th December 2025 ( 08:00am to 16:30pm ) until Wednesday 14th January 2026 at 16:00pm.

Completed bids must be delivered and opened to the address above at **14:00pm on Thursday 15th January 2026.** Late bids will be rejected.

All bids must be accompanied by a bid security in an amount as stated in the bidding document.

Associated bidders are allowed to submit only one bid.

Interested eligible bidders may obtain further information from Procurement Unit of PPWSA at the address above or phone number 017 811 911.